ព្រះគម្ពីរសំរាប់កុមារ
សូមបង្ហាញជូន

# លោកយ៉ាកុប
# មេបោកប្រាស់



និពន្ធដោយ៖ Edward Hughes

ធ្វើការពន្យល់ដោយ៖ M. Maillot; Lazarus
Alastair Paterson

កែសម្រួលដោយ៖ M. Kerr; Sarah S.

បកប្រែដោយ៖ www.christian-translation.com

ផលិតដោយ៖ Bible for Children
www.M1914.org

©2023 Bible for Children, Inc.
អាជ្ញាប័ណ្ណ៖ លោកអ្នកមានសិទ្ធិក្នុងការថតចម្លង ឬបោះពុម្ពរឿងនេះបាន
តែលោកអ្នកមិនអាចយកវាទៅលក់បានទេ។



តើព្រះជាម្ចាស់ពិតជាបាន
ប្រទានឲ្យគ្រួសារមួយ មាន
កូនមែនទេ? ពិតជាអស្ចារ្យ
ខ្លាំងណាស់! លោកអ៊ីសាក
នឹង លោកស្រីរ៉េបេកា ពិតជា
មានក្តីរីករាយដ៏លើសលប់
មែន។ ព្រះជាម្ចាស់នឹង
ប្រទានឲ្យអ្នកទាំង ពីរមាន
កូនភ្លោះ។

ទារកនៅក្នុងផ្ទៃនាងមានការ
ប្រជែងគ្នាយ៉ាងខ្លាំង។
លោកស្រីបានអធិស្ឋាន
ទៅកាន់ព្រះជាម្ចាស់
ព្រះអង្គ
មានព្រះបន្ទូលថា
មានប្រជាជាតិចំនួនពីរ
នៅក្នុងផ្ទៃនាង
ហើយកូនប្អូននឹង
មានអំណាចខ្លាំងជាង។
តាម ធម្មតា
គឺកូនច្បងឯណោះវិញទេ
ដែលមានអំណាចខ្លាំងជាង។
ក្រោយមកទារកទាំងពីរនាក់នោះ
ក៏បាន កើតមក។



ទារកទាំងពីរនាក់នោះ មិនមានលក្ខណៈដូចគ្នានោះទេ។
អេសាវ ជាបង មានរោមពេញខ្លួន ហើយមាន ជំនាញ
ខាងការបរបាញ់សត្វ។ រីឯយ៉ាកុបវិញ មានស្បែកទន់
រលោង ហើយចូលចិត្តការងារផ្ទះ។ លោក អ៊ីសាក់ជា
ឪពុកស្រឡាញ់អេសាវខ្លាំងជាង។ រីឯលោកស្រីរ៉េបេកា
ជាម្ដាយវិញ ស្រឡាញ់យ៉ាកុបខ្លាំងជាង។



ថ្ងៃមួយនោះ អេសាវ បានត្រឡប់មកពីបរបាញ់សត្វវិញ គាត់ឃ្លាន
យ៉ាងខ្លាំង។ គាត់និយាយទៅកាន់ យ៉ាកុបថា  “សូមប្អូនឲ្យម្ហូបបង
ហូបបន្តិចមក” ។ យ៉ាកុបបានឆ្លៀតឱកាសនេះនិយាយថា ៖ “សូម
បងលក់សិទ្ធិជាកូនច្បងឲ្យមក
ខ្ញុំសិនមក”។



លោកអេសាយ មិនយកចិត្តទុកដាក់ចំពោះព្រះបន្ទូលសន្យារបស់ ព្រះជាម្ចាស់ដែលមានចំពោះកូនច្បងនោះទេ។ លោកក៏ព្រមលក់សិទ្ធិជាកូនច្បងនោះឲ្យយ៉ាកុប។ ពេល នេះលោកយ៉ាកុបមានសិទ្ធិជាបងច្បងក្នុងគ្រួសារ ហើយលោកនឹងដឹកនាំគ្រួសារក្រោយពេលឪពុកចែកឋានទៅ។



ព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់លោក អ៊ីសាក់ថា ៖ “យើងជាដែល
អប្រាហាំជាឪពុកអ្នកគោរពបម្រើ។ យើងនឹងស្ថិតនៅជាមួយអ្នក។ យើង
នឹងឲ្យពរដល់ពូជពង្សរបស់អ្នក”។ ថ្វីដ្បិតតែលោកអ៊ីសាក់ ជាអ្នកដែល
ថ្វាយបង្គំព្រះជាម្ចាស់ ឯលោកអេសាវ ជាកូនប្រុសរបស់
លោកវិញ បានយកស្ត្រីសាសន៍ហេតចំនួនពីរនាក់
ជាស្ត្រីដែលមិនគោរពកោតខ្លាចព្រះជាម្ចាស់។





លោកអ៊ីសាក់ កាន់តែចាស់ណាស់ហើយ។ លោកបានប្រាប់អេសាវថា ៖ “ចូរធ្វើម្ហូបយ៉ាងឆ្ងាញ់ តាមឪពុកចូលចិត្ត ហើយយកមកអោយឪពុកបរិភោគ។ ឪពុកនឹងអោយពរកូន”។ ការឲ្យពរដ៏ពិសេសនេះ គឺមានសម្រាប់កូនច្បង។ លោកអេសាវ ក៏ប្រញាប់ចេញទៅបរបាញ់សត្វ។ ប៉ុន្តែលោកស្រីរេបេកា បានស្ដាប់ឮសព្វគ្រប់អស់ហើយ។

លោកស្រីចង់ឲ្យលោកយ៉ាកុបជាអ្នកទទួលពរនោះវិញ។

លោកស្រីរេបេការបានរៀបចំគម្រោងការមួយ។ លោកស្រីបានចម្អិន
ម្ហូបអាហារដែលលោកអ៊ីសាក់ចូល ចិត្ត រីឯលោកយ៉ាកុបវិញ បានយក
សម្លៀកបំពាក់របស់លោកអេសាវមកពាក់ ហើយយកស្បែកសត្វដែល
មានរោមមកពាក់លើដៃ
និង លើ-ក របស់លោកផង។
លោកអ៊ីសាក់មើលមិនឃើញច្បាស់ទេ។
ដូច្នេះហើយ ប្រហែលជាពួកគេអាច
បោកបញ្ឆោតលោកបាន។



លោកយ៉ាកុបបាននាំម្ហូបមកជូន
លោកអ៊ីសាក់ជាឪពុក។
លោកអ៊ីសាក់មានប្រសាសន៍ថា ៖
“សម្លេងកូនដូចសម្លេងយ៉ាកុប តែដៃជាដៃ
របស់អេសាវ”។ ក្រោយពីលោកបានពិសា
រអាហារនោះរួចហើយ លោកអ៊ី
សាក់ក៏បានឲ្យពរដោយកូនប្រុសបានលុត
ជង្គង់ចុះនៅចំពោះមុខលោកផង។



ពេលយ៉ាកុបចាកចេញបានបន្តិច លោកអេសាវក៏បានចូលមករកលោក
អ៊ីសាក់ ជាឪពុក ហើយជម្រាប លោកថា ៖ “សូមអញ្ជើញលោកឪពុក
ក្រោកឡើង ពិសាសាច់ដែលកូនបាញ់បាននេះទៅ រួចសឹម
អោយពរកូន”។ លោកអ៊ីសាក់បានដឹងថា
លោកបានចាញ់បោកគេហើយ។
លោកក៏យំហើយមានប្រសាសន៍
ថា ៖ “ពុកមិនអាចផ្លាស់ប្តូរព្រះ
ពរនោះបានទេ”។
ចិត្តរបស់លោកអេសាវ
ពេញទៅដោយការស្អប់
ហើយលោកបានសម្រេចចិត្តនឹង
សម្លាប់យ៉ាកុបចោល។



លោកស្រីរេបេកា បានដឹងពីបំណងរបស់អេសាវ។ គាត់ក៏បានប្រាប់
លោកយ៉ាកុបថា ៖ ចូរកូនធ្វើដំណើរ ទៅស្នាក់ផ្ទះឪពុកធំរបស់កូនរហូត
ដល់បងរបស់កូនត្រជាក់ចិត្តហើយបំភ្លេច
អ្វីដែលកូនបានធ្វើចំពោះគេ
សឹមកូនត្រឡប់មកវិញ។
លោកអ៊ីសាក់ក៏យល់ស្របថា
យ៉ាកុប ត្រូវយកពីប្រពន្ធពីចំណោមញាតិ
សន្តានរបស់ម្ដាយរបស់គាត់។
ដូច្នេះយ៉ាកុប

ក៏ចាកចេញពីផ្ទះ។



នៅយប់នោះ លោកយ៉ាកុបបាន
ឈប់សម្រាកដោយយកថ្មមក
ធ្វើខ្នើយកើយ។
ប្រហែលលោកយល់ថា
លោកមានតែម្នាក់ឯង
ហើយប្រហែលជាមាន
ការភ័យខ្លាចផង។



ប៉ុន្តែតាមពិតទៅ
លោកមិនមែននៅ
តែម្នាក់ឯងនោះទេ។
ព្រះជាម្ចាស់បានមានព្រះ
បន្ទូលមកកាន់លោក
ក្នុងសុបិន្តនិមិត្ត
ដ៏អស្ចារ្យមួយ។





ព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់លោកថា ៖
“យើងជាព្រះអម្ចាស់ ជាព្រះរបស់អប្រាហាំ ជីតាអ្នក ហើយក៏ជាព្រះរបស់អ៊ីសាកដែរ។ យើងនឹងស្ថិតនៅជាមួយអ្នក។ យើងនឹងប្រគល់ទឹកដីនេះដល់អ្នក។ ក្រុមគ្រួសារទាំងអស់នៅលើផែនដីនឹងបានទទួលពរដោយសារអ្នក”។ លោកយ៉ាកុបក៏បានភ្ញាក់ឡើង ហើយលោកមានការភ័យខ្លាចយ៉ាងខ្លាំង។

លោកឡាបាន់ ជាឪពុកធំរបស់លោកយ៉ាកុប បានមកទទួលលោក។
លោកយ៉ាកុបចាប់ចិត្តស្រឡាញ់ នាងរ៉ាជែល
ដែលត្រូវជាប្អូនជីដូនមួយនឹងលោក
ហើយលោកនៅបម្រើលោក
ឡាបាន់ចំនួនប្រាំពីរឆ្នាំ
ដើម្បីរៀបការជាមួយនាង។



ប៉ុន្តែនៅយប់ថ្ងៃរៀបការនោះ
លោកឡាបាន់បាន
បញ្ឆោតលោកយ៉ាកុប។

លោកយ៉ាកុបបានរអ៊ូរទាំថា ៖ “នេះជាឡេអា មិនមែនរ៉ាជែលទេ លោកអ៊ុំបោកប្រាស់ខ្ញុំហើយ”។ លោក ឡាបាន់ មានប្រសាសន៍ថា ៖ “តាមទម្លាប់ កូនស្រីច្បងត្រូវរៀបការមុន ឥឡូវនេះ ឯងអាចរៀបការជា មួយរ៉ាជែលបានហើយ ប៉ុន្តែឯងត្រូវបម្រើអ៊ុំប្រាំពីរឆ្នាំទៀត”។ លោកយ៉ាកុបក៏យល់ព្រម។ ប្រហែលជា លោកបាននឹកឃើញការដែលលោកបានបោកប្រាស់លោកអ៊ីសាក់ និង



លោកអេសាវ ហើយមើលទៅ។


លោកយ៉ាកុប មានកូនប្រុសចំនួនដប់មួយ
នាក់។ ពេលវេលាបានកន្លងទៅជាយូរឆ្នាំ
ហើយ លោកក៏បាន នាំក្រុមគ្រួសារត្រឡប់
ទៅស្រុកកាណានវិញ។ ឪពុកម្ដាយរបស់
បានស្នាក់នៅក្នុងស្រុកនោះ។ ប៉ុន្តែក៏មាន
អេសាវ ដែលប៉ុនប៉ងសម្លាប់លោក ក៏នៅទី
នោះដែរ។ តើពិតជាមានសុវត្ថិភាពទេ?

ថ្ងៃមួយ ព្រះជាម្ចាស់ បានមានព្រះបន្ទូល
ប្រាប់លោកឲ្យត្រឡប់ទៅផ្ទះវិញ។ លោក
យ៉ាកុបបានប្រមូលក្រុមគ្រួសារ និង ហ្វូង
សត្វរបស់លោកត្រឡប់ទៅផ្ទះវិញ។





ដំណើរនោះពិតជាអស្ចារ្យមែន! លោកអេសាវបានធ្វើដំណើរកាត់មកជួបលោកយ៉ាកុបទាំងនាំមនុស្សបួនរយនាក់មកជាមួយផង។ ប៉ុន្តែ លោកមិនបានធ្វើអ្វីមួយដែលនាំឲ្យលោកយ៉ាកុបឈឺចាប់ទេ។

ផ្ទុយទៅវិញ លោកបានរត់មកជួប
ហើយឱបលោកយ៉ាកុបយ៉ាង
ណែនផង។ លោកយ៉ាកុប និង
លោកអេសាវ ក៏មានភាព
ស្និទ្ធស្នាលគ្នាឡើងវិញ ហើយ
លោកយ៉ាកុប ក៏បានវិលត្រឡប់
ទៅវិញដោយសុវត្ថិភាព។



លោកយ៉ាកុប មេបោកប្រាស់

រឿងមួយពីព្រះបន្ទូលរបស់ព្រះជាម្ចាស់, ព្រះគម្ពីរ,

អាចរកឃើញនៅក្នុង

លោកុប្បត្តិ ២៥-៣៣

“ការស្វែងយល់ព្រះបន្ទូលរបស់ព្រះអង្គ ធ្វើឲ្យមនុស្សភ្លឺស្វាង ហើយធ្វើឲ្យអ្នកទន់ទាបមានប្រាជ្ញា។”
ទំនុកតម្កើង 119:130

ចប់

រឿងព្រះគម្ពីរនេះប្រាប់យើងពីព្រះជាម្ចាស់ដ៏អស្ចារ្យរបស់
យើងដែលបានបង្កើតយើងមក ហើយចង់អោយអ្នកស្គាល់ទ្រង់។

ព្រះអង្គជ្រាបថា យើងបានប្រព្រឹត្តអំពើអាក្រក់, ដែលទ្រង់ហៅការទាំងនោះថា
ជា អំពើបាប។ ទោសនៃអំពើបាបគឺសេចក្តីស្លាប់, ប៉ុន្តែព្រះទ្រង់ស្រឡាញ់យើង
ខ្លាំងណាស់ ដល់ម្ល៉េះហើយបានជាទ្រង់បានចាត់ព្រះយេស៊ូដែលជាព្រះរាជបុត្រា
តែមួយរបស់ព្រះអង្គអោយមកសុគតនៅលើឈើឆ្កាង ហើយបង់ថ្លៃនៃទោស
នោះជំនួសយើង។ ព្រះយេស៊ូបានរស់ពីសុគតឡើងវិញ ហើយបានយាងត្រលប់ទៅ
ស្ថានសួគ៌! ប្រសិនបើអ្នកជឿលើព្រះយេស៊ូ ហើយសុំទ្រង់អោយអភ័យទោសចំពោះ
អំពើបាបរបស់អ្នក, ទ្រង់នឹងលើកលែងទោសអោយអ្នក! ទ្រង់នឹងមក ហើយរស់
ក្នុងចិត្តរបស់អ្នកឥឡូវនេះ, ហើយអ្នកនឹងរស់នៅជាមួយទ្រង់ជារៀងរហូត។

ប្រសិនបើអ្នកជឿថានេះជាការពិត, អ្នកត្រូវទូលទៅកាន់ព្រះអង្គថា៖ ឱព្រះយេស៊ូ
ទូលបង្គំជឿហើយថាទ្រង់ជាព្រះ ហើយបានក្លាយជាមនុស្សម្នាក់មកដើម្បីសុគត
ជំនួសអំពើបាបរបស់ទូលបង្គំ, ហើយពេលនេះទ្រង់រស់ពីសុគតឡើងវិញ។ សូម
ទ្រង់យាងចូលក្នុងជីវិតរបស់ទូលបង្គំ ហើយអភ័យទោសចំពោះអំពើបាបរបស់
ទូលបង្គំ ដើម្បីទូលបង្គំអាចមានជីវិតថ្មីនាពេលឥឡូវនេះបាន ហើយថ្ងៃមួយទូល
បង្គំនឹងទៅនៅជាមួយទ្រង់ជារៀងរហូត។ សូមជួយទូលបង្គំអោយគោរពទ្រង់
ហើយរស់នៅសំរាប់ទ្រង់ដូចជាបុត្ររបស់ទ្រង់។ អាម៉ែន។

សូមអានព្រះគម្ពីរ ហើយអធិដ្ឋានទៅព្រះជារៀងរាល់ថ្ងៃ!   យូហាន ៣៖១៦